ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី
លេខ : ៧៨
ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣
សាលដីកា
លេខ : ០៤ "ង"
ចុះថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០១៤

# សាលដីកា

## នាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាសវនាការជាសាធារណៈនៅថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០១៤។

### សមាសភាពក្រុមប្រឹក្សាជំនុំជំរះ

១-ឯកឧត្តម [redacted] ជាប្រធាន
២-លោក ជាចៅក្រុម
៣-លោក ជាចៅក្រុម
៤-លោក ជាចៅក្រុម
៥-លោក ជាចៅក្រុម

### ក្រឡាបញ្ជី

លោកស្រី [redacted]

### តំណាងមហាអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញា

**ដើមចោទៈលោក** [redacted] ផូ (ម្ចាស់បណ្ដឹងសាទុក្ខ) អាយុ ៦២ឆ្នាំ ជាតិខ្មែរ មុខរបរបម្រើកងហោះហើរដឹកជញ្ជូនសម្ដេចអគ្គសេនាបតីតេជោ ហ៊ុន សែន មានទីលំនៅភូមិថ្មី ឃុំ-ស្រុកតាខ្មៅ ខេត្តកណ្ដាល។

**មេធាវី :** លោក [redacted] តំណាងដោយអាណត្តិ

**ចុងចម្លើយៈអ្នកស្រី** [redacted] វិណ្ណថង (ចុងបណ្ដឹងសាទុក្ខ) អាយុ ៦២ ឆ្នាំ ជាតិខ្មែរ មុខរបរមន្ត្រីចូលនិវត្តន៍ ទីលំនៅសព្វថ្ងៃផ្ទះលេខD₁ ភូមិ ០៧ ក្រុម ២២ ផ្លូវលេខ ៩៧ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ។



មហាវិថី សម្ដេចសុធារស, សង្កាត់ចតុមុខ, ខណ្ឌដូនពេញ, កម្ពុជា Sothearos Blvd, Sangkat Chatomuk, Khan Daun Penh, Cambodia

Scanned with CamScanner

<u>អំពីវិវាទ</u>:-សុំលែងលះពីប្រពន្ធឈ្មោះ [redacted] វណ្ណថង

-សុំសិទ្ធិគ្រប់គ្រងផ្ទះលេខ៦១ ភូមិ០៧ ក្រុម២២ ផ្លូវលេខ៩៧ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ។

## <u>អំពីអង្គហេតុ និង ចំណុចវិវាទៈ</u>

<u>ក-អំពីអង្គហេតុជាមូលហេតុនៃការទាមទារៈ</u>

តាមពាក្យបណ្តឹង ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១២ របស់ដើមចោទឈ្មោះ [redacted] ផូ បានបញ្ជាក់ថា ខ្លួនមានប្រពន្ធហើយ ខ្លួនក៏ទៅទាក់ទងជាមួយឈ្មោះ [redacted] វណ្ណថង ដែលជាស្រីកំណាន់ចិត្តរហូតមានកូន ២នាក់ ហើយមើលឃើញជីវភាពខាង [redacted] វណ្ណថង មានការខ្វះខាត ទើបរូបខ្លួនយកកូនស្រីទាំងពីរមកចិញ្ចឹមបីបាច់ជាមួយប្រពន្ធ បន្ទាប់មកប្រពន្ធខ្លួនបានស្លាប់ទៅ ចំណែកខ្លួនជាប់រវល់បម្រើការងារនៅអង្គភាពទាំងយប់ ទាំងថ្ងៃ ស្រាប់តែឈ្មោះ [redacted] វណ្ណថង ដែលជាម្តាយរបស់កូនទាំងពីរនាក់បានឡើងមករស់នៅលើផ្ទះរបស់ខ្លួនដោយគ្មានការអនុញ្ញាតពីខ្លួនដែលជាម្ចាស់ផ្ទះសោះ។ ហើយកន្លងមកខ្លួនបានប្តឹងទៅអាជ្ញាធរសង្កាត់បឹងត្របែកផងដែរ ហើយអាជ្ញាធរសង្កាត់បានកោះហៅឈ្មោះ [redacted] វណ្ណថង អោយចូលមកដោះស្រាយ តែឈ្មោះ [redacted] វណ្ណថង ពុំចូលខ្លួនមកដោះស្រាយតាមកាលកំណត់ឡើយ។

**បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៤៩ "ណ" ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ សាលាដំបូងរាជធានីភ្នំពេញ សំរេច :**

១-អោយដើមចោទឈ្មោះ [redacted] ផូ និង ចុងចម្លើយឈ្មោះ [redacted] វណ្ណថង ផ្តាច់សមគ្គសង្វាសពីគ្នា យោងតាមមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី។

២-អោយឈ្មោះ [redacted] វណ្ណថង ស្ថិតក្នុងភាពមេម៉ាយចំនួន ១២០ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ យោងតាមមាត្រា ៩៥០ នៃក្រមរដ្ឋប្បវេណី។

៣-ទ្រព្យសម្បត្តិដោយឡែករួមមានផ្ទះលេខ៦១ មានទីតាំងស្ថិតនៅភូមិ ៧ ក្រុម ២២ ផ្លូវ ៩៧ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ មានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១២០១១១០៧-០០៤៨ ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១០ ប្រគល់អោយទៅដើមចោទឈ្មោះ [redacted] ផូ គ្រប់គ្រងជាកម្មសិទ្ធិផ្តាច់មុខ យោងតាមមាត្រា ៩៧២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

៥-សាលក្រមនេះបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២។



Scanned with CamScanner

អំពីវិវាទៈ-សុំលែងលះពីប្រពន្ធឈ្មោះ [redacted] វណ្ណថង

-សុំសិទ្ធិគ្រប់គ្រងផ្ទះលេខD១ ភូមិ០៧ ក្រុម២២ ផ្លូវលេខ៩៧ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ។

## អំពីអង្គហេតុ និង ចំណុចវិវាទៈ

### ក-អំពីអង្គហេតុជាមូលហេតុនៃការទាមទារៈ

តាមពាក្យបណ្តឹង ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១២ របស់ដើមចោទឈ្មោះ [redacted] ផូ បានបញ្ជាក់ថា ខ្លួនមានប្រពន្ធហើយ ខ្លួនក៏ទៅទាក់ទងជាមួយឈ្មោះ [redacted] វណ្ណថង ដែលជាស្រីកំណាន់ចិត្តរហូតមានកូន ២នាក់ ហើយមើលឃើញជីវភាពខាង [redacted] វណ្ណថង មានការខ្វះខាត ទើបរូបខ្លួនយកកូនស្រីទាំងពីរមកចិញ្ចឹមបីបាច់ជាមួយប្រពន្ធ បន្ទាប់មកប្រពន្ធខ្លួនបានស្លាប់ទៅ ចំណែកខ្លួនជាប់រវល់បម្រើការងារនៅអង្គភាពទាំងយប់ ទាំងថ្ងៃ ស្រាប់តែឈ្មោះ [redacted] វណ្ណថង ដែលជាម្តាយរបស់កូនទាំងពីរនាក់បានឡើងមករស់នៅលើផ្ទះរបស់ខ្លួនដោយគ្មានការអនុញ្ញាតពីខ្លួនដែលជាម្ចាស់ផ្ទះសោះ។ ហើយកន្លងមកខ្លួនបានប្តឹងទៅអាជ្ញាធរសង្កាត់បឹងត្របែកផងដែរ ហើយអាជ្ញាធរសង្កាត់បានកោះហៅឈ្មោះ [redacted] វណ្ណថង អោយចូលមកដោះស្រាយ តែឈ្មោះ [redacted] វណ្ណថង ពុំចូលខ្លួនមកដោះស្រាយតាមកាលកំណត់ឡើយ។

**បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៤៩ "ណ" ចុះថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០១២ សាលាដំបូងរាជធានីភ្នំពេញ សំរេច ៈ**

១-អោយដើមចោទឈ្មោះ [redacted] ផូ និង ចុងចម្លើយឈ្មោះ [redacted] វណ្ណថង ផ្តាច់សមគ្គសង្វាសពីគ្នា យោងតាមមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី។

២-អោយឈ្មោះ [redacted] វណ្ណថង ស្ថិតក្នុងភាពមេម៉ាយចំនួន ១២០ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ យោងតាមមាត្រា ៩៥០ នៃក្រមរដ្ឋប្បវេណី។

៣-ទ្រព្យសម្បត្តិដោយឡែករួមមានផ្ទះលេខD១ មានទីតាំងស្ថិតនៅភូមិ ៧ ក្រុម ២២ ផ្លូវ ៩៧ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ មានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ១២០១១១០៧-០០៤៨ ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១០ ប្រគល់អោយទៅដើមចោទឈ្មោះ លន់ ផូ គ្រប់គ្រងជាកម្មសិទ្ធិផ្តាច់មុខ យោងតាមមាត្រា ៩៧២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

៥-សាលក្រមនេះបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០១២។



Scanned with CamScanner

*សាលក្រមនេះត្រូវបានឈ្មោះ [redacted] វណ្ណថង ប្តឹងឧទ្ធរណ៍តាមបណ្តឹងលេខ ៣៧៦ ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ លើចំណុចនៃសាលក្រមទាំងមូល ។*

បានឃើញសាលដីការដ្ឋប្បវេណីលេខ ០៨"ក្រVច" ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៣ របស់សាលាឧទ្ធរណ៍សំរេចៈ

១-ច្រានបណ្តឹងឧទ្ធរណ៍របស់ចុងចម្លើយឈ្មោះ [redacted] វណ្ណថង ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៤៩"ណ" ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ។

៣-បង្គាប់អោយដើមចោទឈ្មោះ [redacted] ផូ សងប្រាក់ថ្លៃជួសជុលផ្ទះលេខ D១ ផ្លូវលេខ ៩៧ ភូមិ៧ ក្រុម ២២ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ចំនួន ០៣តម្លឹងមាស ទៅឈ្មោះ [redacted] វណ្ណថង ។

៤-ប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ជាបន្ទុករបស់ចុងចម្លើយឈ្មោះ [redacted] វណ្ណថង ។

សាលដីកានេះទាញហេតុផលផ្ទាល់មាត់ និង ប្រកាសជាសាធារណៈនៅថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៣ ។

-បើកផ្លូវប្តឹងសាទុក្ខក្នុងរយៈពេល ០១ខែ គិតពីថ្ងៃបានទទួលសាលដីកានេះ ។

*សាលដីកានេះត្រូវបានឈ្មោះ [redacted] ផូ ប្តឹងសាទុក្ខតាមបណ្តឹងលេខ ១១៧ ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៣ គ្រប់ចំណុចនៃសេចក្តីសំរេចទាំងមូល ។*

**ខ-អំពីសេចក្តីថ្លែងការណ៍របស់គូភាគីៈ**

**ឈ្មោះ** [redacted] **ផូ ធ្វើសេចក្តីថ្លែងការណ៍ថា :** ចុងចម្លើយអះអាង និង ទាមទារថ្លៃជួសជុល តែតាមពិតគ្មានការជួសជុលទេ។ សាលាដំបូងសំរេចអោយដកយកតែទ្រព្យដើមរៀង១ខ្លួន។ តែចុងចម្លើយទាមទារថ្លៃជួសជុល ៣តម្លឹង ហើយសាលាឧទ្ធរណ៍ក៏បានសំរេចអោយខ្លួនសង ទើបខ្លួនមិនសុខចិត្តនឹងការសំរេចនេះ ។

**ឈ្មោះ** [redacted] **វណ្ណថង ធ្វើសេចក្តីថ្លែងការណ៍ថា :** ខ្លួន និង គាត់មានទំនាក់ទំនងគ្នាក្នុងឆ្នាំ ៨៧ ដោយមានការយល់ព្រមពីប្រពន្ធដើមគាត់ រហូតមានកូនស្រីពីរនាក់ ហើយត្រូវគាត់យកទៅចិញ្ចឹម ។ ពេលប្រពន្ធដើមគាត់ស្លាប់ គាត់បានហៅខ្លួនទាំងយប់អោយមកជួយរៀបចំបុណ្យសព ពេលនោះខ្លួនបានទៅខ្ចីពីនាយកសាលាខ្លួន ៥០ ម៉ឺនរៀល និង បានលក់ខ្សែដៃខ្លួនជាង ១តម្លឹង និង ប្រាក់តុងទីនខ្លួនពីរក្បាលទៀត យកមករៀបចំបុណ្យសពនេះ។ ក្រោយចប់ពិធីបុណ្យសព គាត់ក៏បានហៅខ្លួនអោយមកនៅផ្ទះជាមួយគាត់ រហូតដល់ឆ្នាំ ២០០៤ គាត់បែកគំនិតទៅទាក់ទងយកស្រីកោសជប់ ហើយបានចុះទៅនៅជាមួយគ្នា ពេលនោះខ្លួនបានជួសជុលផ្ទះ ហើយផ្ទះនេះពេលទិញខ្លួនក៏បានចូលលុយខ្លះដែរ ដើម្បីធ្វើរបង ។ ក្រោយមកពេលគាត់ត្រឡប់មកវិញក៏បានប្តឹងខ្លួនអោយចុះចេញពីផ្ទះ ។ បច្ចុប្បន្នផ្ទះនេះ ខ្លួន និង កូនកំពង់រស់នៅ ។

**លោក** [redacted] **មេធាវីតំណាងដោយអាណត្តិអោយឈ្មោះ** [redacted] **ផូ ធ្វើសេចក្តីថ្លែងការណ៍ថា :** អង្គហេតុដើមគឺផ្ទះនេះជារបស់ប្តី និង ប្រពន្ធដើមកូនក្តីខ្លួន មិនមែនទ្រព្យរួមទេ ។ ឯទ្រព្យរួមដើមចោទ និង ចុងចម្លើយ



Scanned with CamScanner

៣កន្លែង គឺ :១-ផ្ទះ ១នៅភ្នំពេញ, ២-ផ្ទះល្វែងនៅតាខ្មៅ, ៣-ដី ១កន្លែងនៅតាខ្មៅ ។

បច្ចុប្បន្នផ្ទះកំពង់ជួលអោយគេ ឯដីក៏មិនទាន់លក់ដូរដែរ តែកូនក្តីខ្លួនមិនទាមទារទេ គឺសុំយកតែផ្ទះដែលជាទ្រព្យដោយឡែករបស់កូនក្តីខ្លួន តែកូនក្តីខ្លួនមិនសុខចិត្តនឹងការសំរេចអោយគាត់ប្រគល់ថ្លៃជួលសជុលផ្ទះ ៣តម្លឹងទៅចុងចម្លើយ ។ កូនក្តីខ្លួនគ្មានផ្ទះរស់នៅទេ គឺជួលគេនៅ ឯការអះអាងអំពីការជួលសជុល គឺពុំមានទេ ហើយសាលាឧទ្ធរណ៍ក៏ពុំមានសំអាងអំពីការជួសជុលដែរ ។ ហើយកូនក្តីខ្លួនក៏បានអនុញ្ញាតអោយចុងចម្លើយចូលមករស់នៅលើផ្ទះដោយឡែករបស់គាត់ដែរ ។

សំណូមពរ :

១-សុំតម្កល់សាលក្រមសាលាដំបូង

២-សុំគ្រប់គ្រងផ្ទះដែលជាទ្រព្យដោយឡែករបស់កូនក្តីខ្លួន និង ប្រពន្ធដើមគាត់

៣-បើដើមចោទនៅតែទាមទារថ្លៃជួសជុលទៀត កូនក្តីខ្លួននឹងសុំបែងចែកទ្រព្យរួម ៣កន្លែងទៀតដែរ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់គូភាគី និង មេធាវីតំណាង ដោយអាណត្តិរបស់ដើមចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១១៧ ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៣ របស់ភាគីដើមចោទ [redacted] ធ្វើឡើងតាមកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី និង មាត្រា ២៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចតម្កល់សាលក្រមរដ្ឋប្បវេណីរបស់សាលាដំបូងរាជធានីភ្នំពេញ ប៉ុន្តែបែរជាបង្គាប់អោយដើមពាទសងប្រាក់ថ្លៃជួសជុលផ្ទះចំនួន ៣តម្លឹងមាស ទៅអោយចុងចម្លើយនោះ គឺជាការសំរេចផ្ទុយគ្នានឹងសេចក្តីសំរេចត្រង់ចំណុចទី ១ នៃសាលដីកាដែលបានសំរេចច្រានចោលបណ្តឹងឧទ្ធរណ៍របស់ចុងចម្លើយ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ០៨"ក្រIVច"ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៣ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះត្រឹមត្រូវខ្លះ និង មិនត្រឹមត្រូវខ្លះ ។

## ហេតុដូចនេះ

## វិ និ ច្ឆ័ យ សេ ច ក្តី

១-ទទួលផ្នែកខ្លះនៃបណ្តឹងសាទុក្ខលេខ ១១៧ ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៣ របស់ភាគីដើមចោទ [redacted] ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ ០៨"ក្រIVច"ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៣ របស់សាលាឧទ្ធរណ៍ទុកជាបានការ លើកលែងតែសេចក្ដីសំរេចត្រង់ចំណុចទី ៣ ត្រូវបដិសេធចោល ។

៣-បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ ៧៨ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីត្រង់ចំណុចទី ៣ នៃសេចក្ដីសំរេច ។

៤-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ភាគី ចុងចម្លើយ ។

៥-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០១៤។

| | | |
|---|---|---|
| ឯកឧត្ដម | [redacted] | ប្រធាន |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោកស្រី | | ក្រឡាបញ្ជី |

---

បានចតចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ភ្នំពេញថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៤

ក្រឡាបញ្ជី

[redacted]

បានឃើញ

ភ្នំពេញថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៤

ប្រធាន

[redacted]



Scanned with CamScanner